ហ្វូតាបា មីក្រូហិរញ្ញវត្ថុ ភីអិលស៊ី
FUTABA MICROFINANCE PLC.

ឱកាសការងារ

គ្រឹះស្ថាន **ហ្វូតាបា** មីក្រូហិរញ្ញវត្ថុ ភីអិលស៊ី ទទួលបានអាជ្ញាប័ណ្ណផ្លូវការពីធនាគារជាតិនៃកម្ពុជានៅថ្ងៃទី១៦ ខែធ្នូ ឆ្នាំ២០១៥ និងបានចាប់ផ្តើមប្រតិបត្តិការអាជីវកម្មពី **ថ្ងៃទី០១ ខែមករា ឆ្នាំ២០១៦** ដោយសម្រេចបាននូវភាពជោគជ័យ និងការរីកចម្រើនយ៉ាងឆាប់រហ័ស។ ជាក់ស្តែង **ហ្វូតាបា** បានពង្រីកតំបន់ប្រតិបត្តិការរបស់ខ្លួនជាបន្តបន្ទាប់ ដោយបានដាក់ ឲ្យដំណើរការការិយាល័យសាខាថ្មីបន្ថែមចំនួនបួន (៤) បន្ថែមទៀត រួមមានរាជធានីភ្នំពេញចំនួនពីរសាខា (២) សាខាក្រុងច្បារមន ចំនួនមួយ (១) និងសាខាក្រុងដូនកែវ ចំនួនមួយ (១) ដែលជាសាខាថ្មីចាប់បើកដំណើរការនៅក្នុងខែមីនា ឆ្នាំ២០២៣។ បច្ចុប្បន្ន **ហ្វូតាបា** ត្រូវការជ្រើសរើសបុគ្គលិក ដែលមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ ដើម្បីបម្រើការងារក្នុងមុខតំណែងដូចខាងក្រោម ៖

មុខតំណែង	ចំនួនជ្រើសរើស	សាខា	ទីតាំងការងារ
មន្ត្រីហ្វឹកហ្វឺន និងជ្រើសរើសបុគ្គលិកជាន់ខ្ពស់	០១ នាក់	ការិយាល័យកណ្តាល	រាជធានីភ្នំពេញ

កាតព្វកិច្ច និងការទទួលខុសត្រូវ

- គ្រប់គ្រង រៀបចំ ផែនការយុទ្ធសាស្ត្រ ជ្រើសរើសបុគ្គលិក ស្របតាមផែនការដែលបានដាក់ចេញដោយគណៈគ្រប់គ្រង។
- សិក្សាស្រាវជ្រាវ និងផ្តួចផ្តើម អភិវឌ្ឍន៍ អត្ថប្រយោជន៍ចាំបាច់ថ្មីៗ ជូនដល់បុគ្គលិកហ្វូតាបា។
- ទំនាក់ទំនងជិតស្និតគ្រប់ផ្នែកជំនាញទាំងខាងក្នុង និងខាងក្រៅ ដើម្បីផ្សព្វផ្សាយជ្រើសរើសបុគ្គលិក បានទាន់ពេលវេលា។
- រៀបចំ អភិវឌ្ឍន៍នីតិវិធីជ្រើសរើសបុគ្គលិក ប្រកបដោយភាពច្បាស់លាស់ គ្រប់គ្រាន់ ទាន់ពេល។
- ចូលរួមជាមួយផ្នែកជំនាញពាក់ព័ន្ធ ធ្វើការសម្ភាសន៍ជ្រើសរើសបុគ្គលិកប្រកបដោយប្រសិទ្ធភាពខ្ពស់។
- ចុះ Home Visit ប្រមូលព័ត៌មាន ពាក់ព័ន្ធបុគ្គលិកថ្មី ឱ្យបានច្បាស់លាស់ ដើម្បីស្នើសុំការអនុម័តពីថ្នាក់គ្រប់គ្រង។
- រៀបចំ និងគ្រប់គ្រងឯកសាររបស់បុគ្គលិក (Staff Profile) ឱ្យបានត្រឹមត្រូវ។
- ធ្វើរបាយការណ៍ជូនថ្នាក់គ្រប់គ្រងផ្ទាល់។
- គ្រប់គ្រង រៀបចំបន្ទប់ហ្វឹកហ្វឺន ឧបករណ៍-សម្ភារៈ ឯកសារមេរៀនទាំង Hard copy និង Soft copy។
- រៀបចំតារាងកាលវិភាគហ្វឹកហ្វឺន ប្រចាំឆ្នាំ និងកម្មវិធីហ្វឹកហ្វឺនផ្សេងៗ ស្របតាមផែនការអភិវឌ្ឍន៍ធនធានមនុស្ស ដែលបានដាក់ចេញដោយគណៈគ្រប់គ្រង។

លក្ខខណ្ឌជ្រើសរើស

- បញ្ចប់ថ្នាក់បរិញ្ញាបត្រផ្នែកគ្រប់គ្រងធនធានមនុស្ស ឬសញ្ញាបត្រដែលមានតម្លៃស្មើ។
- មានបទពិសោធយ៉ាងតិច០២ឆ្នាំ ពាក់ព័ន្ធការងារជ្រើសរើសបុគ្គលិក ការងាររៀបចំ ហ្វឹកហ្វឺន បណ្តុះបណ្តាលបុគ្គលិក។
- មានជំនាញក្នុងការទំនាក់ទំនង មានភាពស្មោះត្រង់ និងអាចធ្វើការងារជាក្រុម។
- មានចំណេះដឹងភាសាអង់គ្លេស អាចសរសេរ និងនិយាយបាន ល្អ។
- អាចប្រើប្រាស់កុំព្យូទ័រ Ms Office Word & Ms Excel។
- ចេះបើកបរម៉ូតូ។
- ផ្តល់អទិភាពដល់អ្នកដែលធ្លាប់បម្រើការងារ នៅភ្នំពេញ។

អគារលេខ៧៩៥ មហាវិថីព្រះមុនីវង្ស សង្កាត់បឹងត្របែក ខណ្ឌចំការមន រាជធានីភ្នំពេញ
(៨៥៥) ២៣ ២២៤ ៣៣៣, ទូរសារ: (៨៥៥) ២៣ ២២២ ១៣១
info@futabamfi.com.kh www.futabamfi.com.kh Futaba Microfinance Plc.

- សហការ សម្របសម្រួលជាមួយគ្រប់ផ្នែកជំនាញ ក្នុងការរៀបចំកម្មវិធីវគ្គបណ្តុះបណ្តាលជូនដល់បុគ្គលិកថ្មី បុគ្គលិកកំពុងបម្រើការងារ និងបុគ្គលិកដែលបានផ្លាស់ប្តូរមុខងារ តួនាទី។ - បណ្តុះបណ្តាលបុគ្គលិកចូលថ្មី អំពីគោលការណ៍ និងនីតិវិធីរបស់គ្រឹះស្ថានពាក់ព័ន្ធនឹងផ្នែកធនធានមនុស្ស។ - ចូលរួមតម្រង់ទិស បណ្តុះវិន័យសិក្សា ជូនសិក្ខាកាម ដើម្បីរក្សាសណ្តាប់ធ្នាប់ និងរបៀបរៀបរយល្អក្នុងពេលសិក្សា។ - ពិនិត្យ និងតាមដានសកម្មភាពគ្រូហ្វឹកហ្វឺន / សិក្ខាកាម ក្នុងពេលកំពុងបណ្តុះបណ្តាល និងធ្វើការវិភាគលើកម្រិតយល់ដឹងរបស់សិក្ខាកាម ដើម្បីបូកសរុបលទ្ធផលនៃការហ្វឹកហ្វឺន ព្រមទាំងរៀបចំរបាយការណ៍ ស្តីពីការវាយតម្លៃវគ្គហ្វឹកហ្វឺន ជូនអ្នកគ្រប់គ្រង។ - រៀបចំលិខិតបញ្ជាក់វិញ្ញាបនប័ត្របញ្ជាក់ ការសិក្សាជូនដល់សិក្ខាកាម។ - ធ្វើកិច្ចការផ្សេងៗ តាមការចាត់តាំងរបស់អ្នកគ្រប់គ្រង។	

គ្រឹះស្ថាន **ហ្វូតាបា** មីក្រូហិរញ្ញវត្ថុ ភីអិលស៊ី ផ្តល់ជូនបុគ្គលិកពេញសិទ្ធិនូវ អត្ថប្រយោជន៍ផ្សេងៗដូចជា៖

១. ផ្តល់ប្រាក់បៀវត្សប្រកួតប្រជែងទៅតាមបទពិសោធន៍។ ២. ប្រាក់ឧបត្ថម្ភបុណ្យចូលឆ្នាំខ្មែរ ១០០% នៃប្រាក់បៀវត្ស។ ៣. ប្រាក់ឧបត្ថម្ភបុណ្យភ្ជុំបិណ្ឌ ១០០% នៃប្រាក់បៀវត្ស។ ៤. ការធានារ៉ាប់រងសុខភាពដល់បុគ្គលិក និងសមាជិកគ្រួសារ (ប្តី/ប្រពន្ធ និងកូន២នាក់)។ ៥. ការធានារ៉ាប់រងគ្រោះថ្នាក់ដល់ជីវិត ២៤ ម៉ោង។ ៦. ប្រាក់ឧបត្ថម្ភចំណងដៃ អាពាហ៍ពិពាហ៍បុគ្គលិក។ ៧. ផ្តល់ប្រាក់កម្ចីដល់បុគ្គលិកក្នុងអត្រាការប្រាក់សមរម្យ។	៨. ការឈប់សម្រាកអនុលោមតាមច្បាប់ក្រសួងការងារ និងការឈប់សម្រាកប្រចាំឆ្នាំ។ ៩. ប្រាក់ឧបត្ថម្ភ និងសម្ភារៈប្រើប្រាស់ផ្សេងៗ តាមគោលការណ៍កំណត់របស់គ្រឹះស្ថាន **ហ្វូតាបា**។

- **<u>របៀបដាក់ពាក្យ៖</u>** បេក្ខជន / បេក្ខនារី ដែលមានចំណាប់អារម្មណ៍បំពេញការងារជាមួយ គ្រឹះស្ថាន ***<u>ហ្វូតាបា</u>*** មីក្រូហិរញ្ញវត្ថុ ភីអិលស៊ី សូមផ្ញើពាក្យសុំបម្រើការងារ (CV និង Cover Letter) ជាមួយរូបថត (4x6) ដោយបញ្ជាក់ពីមុខតំណែង និងទីតាំងដែលចង់បម្រើការងារឲ្យបានច្បាស់លាស់ និងយកមកដាក់នៅតាមការិយាល័យសាខារបស់ ហ្វូតាបា ឬអាចផ្ញើមកតាមរយៈ:

  Email: Recruitment@futabamfi.com.kh (នាយកដ្ឋានធនធានមនុស្ស) ។
- សូមបញ្ជាក់ឲ្យបានច្បាស់លាស់អំពីប្រាក់បៀវត្សរំពឹងទុក។
- **<u>ឈប់ទទួលពាក្យត្រឹម៖</u>** ***<u>ថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០២៥ ម៉ោង០៥:០០ល្ងាច</u>*** *(អ្នកដាក់ពាក្យមុនត្រូវបានលើកទឹកចិត្ត)*
- **<u>សម្រាប់ព័ត៌មានបន្ថែម៖</u>** សូមទំនាក់ទំនងផ្នែកធនធានមនុស្ស ទូរស័ព្ទលេខ: 070 479 333 ឬចូលទៅកាន់គេហទំព័រ www.futabamfi.com.khឬ Facebook Futaba Microfinance Plc.

(បេក្ខជន ឬបេក្ខនារី ដែលបានដាក់ពាក្យរួចហើយមិនអាចដកពាក្យវិញបានឡើយ)